Khmer

Australian Government

# កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ជំនួយផ្នែកការងារដែលមានភាពបត់បែន និងរៀបចំកែតម្រូវ

កិច្ចបំរើរកការងារធ្វើថ្មីសំរាប់អ្នកមានពិការភាពតម្លៃ១.២កោដិដុល្លា និងប្រសើរជាងមុនរបស់រដ្ឋាភិបាលអូស្ត្រាលី នឹងផ្តល់ជូននូវជំនួយផ្នែកការងារដែលកាន់តែមានប្រសិទ្ធិភាព សំរាប់អ្នកស្វែងរកការងារធ្វើមានពិការភាព ចាប់តាំងពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១០នេះទៅ។

**កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព** នឹងបង្កើននូវការចូលរួមផ្នែកការងាររបស់អ្នកស្វែងរកការធ្វើដែលមានពិការភាព។

កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព មានការរីកចំរើនគួរឲ្យចាប់អារម្មណ៍នៅក្នុងកិច្ចបំរើសំរាប់អ្នកមានពិការភាព គ្រួសារ និងអ្នកមើថែអ្នកទាំងនោះ ហើយនិងនិយោជក។ អ្នកស្វែងរកការធ្វើដែលមានពិការភាពនឹងទទួលបានភ្លាមៗនូវកិច្ចបំរើដែលត្រូវបានរៀបចំកែតម្រូវ និងមានភាពបត់បែន ហើយឆ្លើយតបតាមសេចក្តីត្រូវការរបស់គេ ហើយនិងរបស់និយោជក។

កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាពថ្មី នឹងផ្តល់ចំពោះអ្នកស្វែងរកការធ្វើដែលមានពិការភាព មានរបួស ឬមានបញ្ហាផ្នែកសុខភាព ដើម្បីមានសិទ្ធិទទួលបាននូវកិច្ចបំរើរកការងារធ្វើដែលបានរៀបចំកែតម្រូវសំរាប់បុគ្គលផ្ទាល់ ដើម្បីឲ្យកាន់តែសមស្របទៅតាមសេចក្តីត្រូវការរបស់គេ ដោយការតភ្ជាប់យ៉ាងរឹងមាំ ជាមួយនិងការហ្វឹកហាត់ និងការពង្រីកផ្នែកមុខជំនាញជាពិសេសក្នុងផ្នែកដែលមានការខ្វះខាតអ្នកមានមុខជំនាញក្នុងតំបន់។

មានកម្មវិធីពីរដាច់ដោយឡែកពីគ្នានៅក្នុងរង្វង់ កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព:

- **កិច្ចបំរើគ្រប់គ្រងពិការភាព** គឺសំរាប់អ្នកស្វែងរកការងារធ្វើដែលមានពិការភាព មានរបួស ឬបញ្ហាផ្នែកសុខភាពដែលត្រូវការជំនួយពីកិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ក៏ប៉ុន្តែពុំរំពឹងថាគេមានសេចក្តីត្រូវការឲ្យជួយទ្រទ្រង់នៅកន្លែងធ្វើការក្នុងរយៈពេលយូរអង្វែង
- **កិច្ចបំរើជួយទ្រទ្រង់ផ្នែកការងារ** គឺសំរាប់អ្នកស្វែងរកការងារធ្វើដែលមានពិការភាពជាអចិន្ត្រៃយ៍ ហើយដែលត្រូវបានវាយតម្លៃថាមានសេចក្តីត្រូវការឲ្យជួយទ្រទ្រង់នៅតាមកន្លែងធ្វើការសំរាប់រយៈពេលយូរអង្វែង និងទៀងទាត់។

កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាពថ្មី ជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយ រាប់បញ្ចូលទាំងការអញ្ជើញឲ្យដាក់ពាក្យសុំលើកដំបូង ឯកសារសំរាប់ការពិភាក្សាដែលឆ្លើយតបទៅនឹងការដាក់ពាក្យសុំទាំងនោះ ហើយនិងរយៈពេលពិគ្រោះយោបល់ទូទាំងប្រទេសចំនួនពីរលើក។

## ផ្លូវត្រួសត្រាយដ៏ល្អប្រសើរសំរាប់ការងារ

រដ្ឋាភិបាលអូស្ត្រាលីឲ្យតម្លៃចំពោះវិភាគទានដែលអ្នកមានពិការភាពបានរួមចំណែកដល់សង្គមជាតិអូស្ត្រាលី ហើយជឿជាក់ថាអ្នកដែលមានពិការភាពមានចិត្តចង់ធ្វើការងារ ហើយគួរបានជួយនៅក្នុងការប្រឹងប្រែងរបស់គេ ដើម្បីឲ្យបានការងារធ្វើ និងរក្សាការងារឲ្យបានជាប់លាប់។

កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព នឹងត្រូវបានបើកចំហដើម្បីឲ្យអ្នកមានពិការភាពទាំងអស់ដែលមានសិទ្ធិ អាចទទួលបានកិច្ចបំរើដែលគេត្រូវការបានយ៉ាងឆាប់រហ័ស។ គេពុំចាំបាច់ចុះឈ្មោះក្នុងបញ្ជីរង់ចាំទេ។

គ្រប់អ្នករកការធ្វើដែលមានពិការភាព ហើយមានសិទ្ធិ នឹងទទួលបាននូវកិច្ចបំរើដែលបានរៀបចំកែតម្រូវ ហើយទូលំទូលាយសំរាប់បុគ្គលផ្ទាល់ រាប់បញ្ចូលទាំងការបង្កើនសមត្ថភាព ការហ្វឹកហាត់ បទពិសោធន៍ការងារ ហើយនិងការធ្វើអន្តរាគមន៍ឯទៀត ដើម្បីជួយអ្នកចូលរួមឲ្យទទួលបានការងារធ្វើ និងរក្សាការងារដែលសមស្របឲ្យបានជាប់លាប់។

ស្ថាប័នផ្តល់កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព អាចនឹងប្រឹងប្រែងធ្វើអន្តរាគមន៍ទាន់ពេល ក្នុងឋានៈជាដៃគូជាមួយសាលារៀន និងកិច្ចបំរើឯទៀត ដើម្បីឲ្យប្រាកដថាជំនួយផ្នែកការងារអាចទទួលបានយ៉ាងឆាប់រហ័សនៅពេលណាដែលអ្នកមានពិការភាពបានរៀបចំជាស្រេចដើម្បីនឹងចូលរួម។

Disability™ Employment Services

## លក្ខណៈពិសេសៗនៃកិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព

- ការបើកចំហនៃកិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ដើម្បីឲ្យអ្នកពិការភាពដែលស្វែងរកការងារធ្វើ ពុំចាំបាច់ត្រូវរង់ចាំឲ្យកិច្ចបំរើជួយគេឲ្យបានការងារធ្វើ ហើយជួយរក្សាការងារនោះឲ្យបានជាប់លាប់ថែមទៀត។
- កម្មវិធីផ្សេងគ្នាចំនួនពីរ បានផ្ចង់ស្មារតីទៅលើសេចក្តីត្រូវការខុសគ្នារបស់អ្នកស្វែងរកការងារធ្វើដែលមានពិការភាព ធ្វើឲ្យដំណើរការវាយតម្លៃនិងការបញ្ជូនទៅកន្លែងផ្សេងទៀត ពុំសូវមានភាពស្មុគស្មាញ។
- ផ្តល់នូវជំនួយត្រឹមត្រូវឲ្យទាន់ពេល តាមលទ្ធភាពដែលអាចធ្វើបានរាប់បញ្ចូលទាំងសំរាប់អ្នកទើបនឹងចេញពីសាលា ដើម្បីឲ្យប្រាកដថាការផ្លាស់ប្តូរដើម្បីធ្វើការបានទទួលជោគជ័យ។
- លើកទឹកចិត្តការផ្ចង់ស្មារតីឲ្យរឹងមាំទៅលើលទ្ធផលនៃការរកការងារធ្វើដោយផ្តល់នូវរង្វាន់ធំបំផុត នៅពេលដែលកិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព រកបានការងារសមស្របសំរាប់អ្នកចូលរួម។
- ផ្តល់រង្វាន់លើកទឹកចិត្តដ៏ល្អ ដល់កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ដើម្បីលើកទឹកចិត្តចំពោះការពង្រីកផ្នែកមុខជំនាញការអប់រំ និងការហ្វឹកហាត់។
- រចនាសម្ព័ន្ធនៃការផ្តល់ថវិកា ដែលធនធានផ្តោតទៅលើអ្នកស្វែងរកការងារធ្វើដែលចាញ់ប្រៀបជាងគេ។
- បង្កើនធនធានដើម្បីជួយដល់អ្នកស្វែងរកការងារធ្វើមានពិការភាពដែលនៅតំបន់ឆ្ងាយដាច់ស្រយាល។
- បង្កើតជាផែនការត្រួសត្រាយផ្លូវសំរាប់ការងាររវាង កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព និងអ្នកស្វែងរកការងារធ្វើ ដោយផ្តល់ពត៌មានលំអិតស្តីអំពីកិច្ចបំរើដែលបានរៀបចំកែតម្រូវ ដើម្បីជួយដល់បុគ្គលផ្ទាល់ក្នុងការការពារការងារ។
- វិធីសាស្ត្រដែលមានការបត់បែនដើម្បីឲ្យ កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព អាចផ្តល់កិច្ចអន្តរាគមន៍លាយបញ្ចូលគ្នា សំរាប់ដោះស្រាយឧបសគ្គ ទាំងមុខវិជ្ជាជីវៈ និងពុំមែនមុខវិជ្ជាជីវៈ។
- កាត់បន្ថយបន្ទុកផ្នែករដ្ឋបាល និងច្បាប់ដែលធ្វើឲ្យយឺតដល់ការងារដើម្បីផ្តល់ធនធានឲ្យបានច្រើនដល់ កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ដើម្បីជួយអ្នកស្វែងរកការងារធ្វើឲ្យរកបានការងារនិងរក្សាឲ្យបានជាប់លាប់។
- គ្រប់កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាពទាំងអស់ ត្រូវបានតម្រូវឲ្យធ្វើការបញ្ជាក់អះអាងថាបានគោរពតាមបទដ្ឋាន នៃកិច្ចបំរើពិការភាព។ ចំពោះពត៌មានបន្ថែម សូមបើកមើលវ៉ិបសាយ **www.jobaccess.gov.au**

## ការជួយនិយោជកឲ្យរកបានអ្នកធ្វើការដែលមានមុខជំនាញ

កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាពថ្មី នឹងជូនជារង្វាន់ដល់ស្ថាប័នផ្តល់កិច្ចបំរើ ដែលបានធ្វើការជាមួយនិយោជក ដើម្បីផ្គត់ផ្គង់ឲ្យគេនូវអ្នកស្វែងរកការងារធ្វើ ដែលអាចបំពេញតាមសេចក្តីត្រូវការរបស់ទីផ្សារការងារនិងមុខជំនាញប្រចាំតំបន់។

មូលនិធិសំរាប់ជំនួយផ្នែកការងារ នឹងធ្វើឲ្យស្វែងអ្នករកការងារធ្វើ និយោជកនិងស្ថាប័នផ្តល់កិច្ចបំរើ ទទួលបានធនធានយ៉ាងងាយស្រួល ដើម្បីជួយឲ្យរកបានការងារធ្វើ និងថែរក្សាការងារឲ្យបានជាប់លាប់ ដូចជាការកែប្រែកន្លែងធ្វើការ និងកិច្ចបំរើបកប្រែភាសា Auslan ជាដើម។

ចំពោះអ្នកចូលរួមទាំងនោះ ដែលត្រូវការការជួយទ្រទ្រង់ដើម្បីរក្សាការងាររបស់គេឲ្យបានជាប់លាប់ ការជួយទ្រទ្រង់ជាបន្តទៀត អាចទទួលយកបានពីកិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព គឺឲ្យតែគេមានសេចក្តីត្រូវការ។ នឹងមានការជួយទ្រទ្រង់ជាបន្តទៀតចំនួនបីកំរិត (កំរិតដែលមានភាពបត់បែន កំរិតមធ្យម និងកំរិតខ្ពស់) ដើម្បីបំរើសេចក្តីត្រូវការផ្សេងៗគ្នារបស់អ្នកធ្វើការដែលមានពិការភាព និងនិយោជករបស់គេ។

ការជួយទ្រទ្រង់ជាបន្តទៀតដែលមានភាពបត់បែន គឺជាលក្ខណៈពិសេសថ្មីនឹងផ្តល់នូវប្រព័ន្ធសុវត្ថិភាព សំរាប់អ្នកចូលរួមដែលត្រូវបានដាក់ឲ្យធ្វើការងារ ក៏ប៉ុន្តែជាអ្នកដែលអាចត្រូវការការជួយទ្រទ្រង់ដែលពុំទៀងទាត់ ឬដែលពុំអាចព្យាករណ៍ទុកជាមុនបាន ដើម្បីរក្សាការងាររបស់គេឲ្យបានជាប់លាប់។ ការនេះផ្តល់ឲ្យនូវជំរើសដ៏ប្រសើរសំរាប់អ្នកចូលរួមមួយចំនួនដូចជាអ្នកដែលមានបញ្ហាផ្នែកសុខភាពផ្លូវចិត្ត ឬបញ្ហាសុខភាពពុំទៀងទាត់ជាដើម។

អ្នកចូលរួមជាច្រើននឹងអាចចាកចេញពី កិច្ចបំរើរកការងារធ្វើសំរាប់អ្នកមានពិការភាព ហើយទៅជាអ្នកធ្វើការដោយឯករាជ្យវិញ ពេលណាគេបានចូលធ្វើការងារជាប់លាប់។

0A10-0066_DESFactsheet_March_10